01523612

Declassified to Public
27 June 2019

E319/35/16

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 15 / 08 / 2017
ម៉ោង (Time/Heure): 13:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង** សម្ងាត់ / Confidential / Confidentiel

ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៧

**ជូនចំពោះ៖** **ចៅក្រម Michael BOHLANDER**
**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**

**ពី៖** **ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន៖** **ចៅក្រម យូ ប៊ុនឡេង សហចៅក្រមស៊ើបអង្កេតជាតិ**
**លោក/លោកស្រីចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង**
**មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង**
**ភាគីទាំងអស់ក្នុងសំណុំរឿង ០០២**

**កម្មវត្ថុ៖** **ការសាកសួរពាក់ព័ន្ធនឹងវិធានការការពារសម្រាប់សាក្សីប្រភេទ ក ឈ្មោះ ហែម មឿន (2-TCW-976) (សម្ងាត់)**

១. នៅថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៧ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចមួយ (ឯកសារ E319/35/15) ស្របតាមសេចក្តីសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ("ស.ច.ស.អ") ពាក់ព័ន្ធនឹងលក្ខខណ្ឌតម្រូវចំពោះភាពសម្ងាត់នៅក្នុងសំណុំរឿង ០០២/០២ សម្រាប់សាក្សី និងសម្ភារៈដែលបានដាក់បង្ហាញពីសំណុំរឿង ០០៣ និង ០០៤ (សូមមើល ឯកសារ E319/35/14/2 និង E319/35/14/3)។ ហេតុនេះ អង្គជំនុំជម្រះបានសម្រេចលុបចោលនូវលក្ខខណ្ឌតម្រូវក្នុងការយោងទៅសម្ភារៈ និងសាក្សីនៅក្នុងឧបសម្ព័ន្ធ ១ នៃសេចក្តីសម្រេចនោះដោយប្រើរហស្សនាមសាក្សី (ឯកសារ E319/35/15.1) ហើយក៏បានលុបចោលនូវការកោសលុបនានាចំពោះប្រតិចារឹកទាំងឡាយដែលបានរៀបរាប់នៅក្នុងឧបសម្ព័ន្ធ ២ នៃ

E319/35/16

សេចក្ដីសម្រេចនោះដែរ (ឯកសារ E319/35/15.2)។ ផ្អែកតាមយោបល់របស់ ស.ច.ស.អ. ទាក់ទិននឹងភាពចាំបាច់នៃការរក្សាសុចរិតភាពនៃកិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៤ អង្គជំនុំជម្រះបានរក្សានូវលក្ខខណ្ឌតម្រូវលើភាពសម្ងាត់សម្រាប់សាក្សី និងសម្ភារៈ ដែលបានរៀបរាប់នៅក្នុងឧបសម្ព័ន្ធ ៣ នៃសេចក្ដីសម្រេចចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៧ (ឯកសារ E319/35/15.3) ។

២. នាពេលនេះ អង្គជំនុំជម្រះសាលាដំបូងស្នើសុំយោបល់ពីសហចៅក្រមស៊ើបអង្កេតអន្តរជាតិបន្ថែមទៀតថា តើសុចរិតភាពនៃកិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៤ នៅតែតម្រូវឱ្យរក្សាទុកវិធានការការពារដែលបានអនុវត្តចំពោះសាក្សី ហែម មឿន (2-TCW-976) ដូចដែលបានបញ្ជាក់នៅក្នុងឧបសម្ព័ន្ធ ៣ (ឯកសារ E319/35/15.3) ជាសាក្សីប្រភេទ ក ដដែលទៀតដែរ ឬ យ៉ាងណា។